# សិក្ខាសាលាបណ្តុះបណ្តាលស្តីអំពីភាពជាអ្នកដឹកនាំ ជាមួយតំណាងក្រុមផលិតស្រូវសរីរាង្គ

នៅថ្ងៃទី ០៨-១០ ខែ ឧសភា ឆ្នាំ២០០៩ អង្គការ សេដាក ដោយមានការឧបត្ថម្ភពី **មូលនិធិហ្វ្រីឌ្រិច ណៅម៉ាន់ដើម្បីសេរីភាព** (ជំនួយពីប្រជាជនអាល្លឺម៉ង់) បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមួយស្តីអំពីភាពជាអ្នកដឹក នាំដល់តំណាងក្រុមផលិតស្រូវសរីរាង្គ នៅរមណីយដ្ឋានកំសាន្ត **Picnic** ខេត្តកោះកុង។ កសិករដែលជាតំណាងក្រុមផលិតស្រូវសរីរាង្គចំនួនប្រមាណ ៥៧ នាក់ (ស្រី ៧ នាក់) មកពីខេត្ត តាកែវ កំពត ព្រៃវែង កំពង់ស្ពឺ កំពង់ចាម និងកំពង់ឆ្នាំង ចូលរួមក្នុងសិក្ខាសាលានេះ។ សិក្ខាសាលានេះត្រូវបានសំរបសំរួលដោយ បណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការ សេដាក លោក ឃឹម សុផាណ្ណា អ្នកគ្រប់គ្រងគំរោង អេហ្វអិនអេហ្វ លោកឡាង សេងហ៊ាង នាយកសហគ្រាសសេដាក និងលោកនង សំអាត ប្រធានសហព័ន្ធស្រូវសរីរាង្គថ្នាក់ជាតិ ។

ដោយមើលឃើញពីការរីកចំរើនរបស់សហព័ន្ធសហគមន៍ផលិតស្រូវសរីរាង្គពីមួយទៅមួយឆ្នាំ និងដើម្បីរៀបចំអោយសហគមន៍មានលក្ខណៈស្តង់ដាត្រឹមត្រូវ និងដើម្បីពង្រឹងគណៈកម្មាធិការ ក៏ដូចជាក្រុមអោយមានសមត្ថភាព និងរៀនសូត្របទពិសោធន៍ពីគ្នាទៅវិញទៅមក អង្គការ សេដាក បានរៀបចំជាសិក្ខាសាលានេះឡើង ក្នុងគោលបំនង :

- ផ្តល់ឱកាសរៀនសូត្រពីគ្នាទៅវិញទៅមក (រៀនផង កំសាន្តផង)
- ពង្រឹងការសហការ និងស្មារតីក្រុម
- ពង្រឹងសមត្ថភាពក្នុងភាពជាអ្នកដឹងនាំក្រុម ឬសហគមន៍
- រៀបចំយុទ្ធសាស្ត្រទៅថ្ងៃខាងមុខ

ឆ្លងតាមរយៈការប្រជុំអស់រយៈពេល ៣ថ្ងៃនេះ យើងឃើញថា សិក្ខាកាមចូលរួម មានការពេញចិត្តយ៉ាងខ្លាំង ក្នុងនោះពួកគាត់បានរៀនផងកំសាន្តផង ដែលបានបញ្ច្រាបនូវចំនេះដឹងល្អៗ សំដៅឱ្យពួកគាត់យកចំនេះដឹងទាំងនោះទៅអនុវត្តន៍នៅតាមសហគមន៍។ ក្នុងពេលបណ្តុះបណ្តាល អ្នកសំរបសំរួលបានលើកយករឿងមហាឱសថគន្ធី និងការលេង ល្បែងជាច្រើន ដែលបង្កប់នូវគំនិតភាពជាអ្នកដឹកនាំ ក្នុងគោលបំនងបង្កើនការពង្រឹងសមត្ថភាព ក្នុងការដឹកនាំរបស់សិក្ខាកាមម្នាក់ៗ។

គួរជំរាបជូនថាចាប់តាំងពីឆ្នាំ ២០០៣ មកទីផ្សារ សេដាក បានទិញស្រូវសរីរាង្គពីក្រុមហើយការទិញស្រូវរបស់សហព័ន្ធស្រូវសរីរាង្គនេះ មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ កាលឆ្នាំ ២០០៣ សហព័ន្ធបានទិញស្រូវបានចំនួន ១០ តោនពីក្រុមផលិតចំនួន ១៨ ក្រុម ហើយនៅឆ្នាំ ២០០៨-២០០៩ នេះសហព័ន្ធបានប្រមូលទិញស្រូវបាន ១៣៨០ តោន ។

